ព្រះរាជាណាចក្រកម្ពុជា
ជាតិ  សាសនា  ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ..........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងបើកសិក្ខាសាលាថ្នាក់ជាតិស្តីពី រូបិយវត្ថុ និងអធិបតេយ្យភាព
## ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣០ នៃការបោះផ្សាយប្រាក់រៀលដាក់ឱ្យចរាចរឡើងវិញ
នៅសាលសន្និសីទចតុមុខ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០

សូមគោរព :

- លោក Jean-Daniel Gardère
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក និងកិត្តិយសបំផុត ដោយបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឱ្យធនាគារជាតិនៃកម្ពុជា រៀបចំសិក្ខាសាលាជាតិស្តីពី រូបិយវត្ថុ និងអធិបតេយ្យភាព សម្រាប់ជូនមន្ត្រីរាជការ ធនាគារិក សេដ្ឋវិទូ ប្រវត្តិវិទូ សាស្ត្រាចារ្យ និងនិស្សិតបញ្ញវន្ត ។ តាងនាមឱ្យមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ សម្តេចនាយករដ្ឋមន្ត្រី ដែលបានគាំទ្រឱ្យមានសិក្ខាសាលានេះឡើង ។ ខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះលោក Jean-Daniel Gardère ដែលបានផ្តល់កិត្តិយសអញ្ជើញមកធ្វើបទឧទ្ទេសនាមពេលនេះ ។

ទន្ទឹមពេលនេះដែរ ខ្ញុំសូមស្វាគមន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា តំណាងឱ្យក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គ្រឹះស្ថានឧត្តមសិក្សា ធនាគារិក សេដ្ឋវិទូ ប្រវត្តិវិទូ សាស្ត្រាចារ្យ និងនិស្សិតបញ្ញវន្តទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញ ចូលរួមសិក្ខាសាលារបស់យើងនាថ្ងៃនេះ ។ សិក្ខាសាលានេះ រៀបចំឡើងបន្ទាប់ពីធនាគារជាតិនៃកម្ពុជាបានប្រារព្ធពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ កន្លងមក។

ដើម្បីចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣០ នៃការបោះផ្សាយប្រាក់រៀលដាក់ឱ្យចរាចរឡើងវិញ (២០ មីនា ១៩៨០ - ២០ មីនា ២០១០) ធនាគារ ជាតិនៃកម្ពុជារៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី រូបិយវត្ថុ និងអធិបតេយ្យភាព សម្រាប់ជូនមន្ត្រីរាជការ ធនាគារិក សេដ្ឋវិទូ ប្រវត្តិវិទូ សាស្ត្រាចារ្យ និងនិស្សិតបញ្ញវន្ត

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

បានសិក្សាស្វែងយល់ពីអត្ថន័យនិងសារៈសំខាន់នៃ ការបោះផ្សាយប្រាក់រៀលដាក់ឱ្យចរាចរឡើងវិញ និងតួនាទីស្ថាប័នហិរញ្ញវត្ថុក្នុងការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក្នុងរយៈពេល ៣០ឆ្នាំកន្លងមក ក្រោយពីថ្ងៃមហាជ័យជំនះ ៧ មករា លើរបបប្រល័យពូជសាសន៍ប៉ុល ពត ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី និង នាងកញ្ញា ជាទីមេត្រី

ឆ្លៀតឱកាសពេលនេះ ខ្ញុំសូមជម្រាបជូនពីសារៈសំខាន់នៃប្រវត្តិសាស្ត្រ ប្រវត្តិរូបិយវត្ថុនៅកម្ពុជា និងពីតួនាទីប្រព័ន្ធរូបិយវត្ថុនិងហិរញ្ញវត្ថុក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច ដូចតទៅ :

១/-សារៈសំខាន់នៃប្រវត្តិសាស្ត្រ : ប្រវត្តិសាស្ត្រមានសារៈសំខាន់ណាស់សម្រាប់មនុស្សជាតិ ។ វាប្រាប់យើងពីរឿងរ៉ាវអតីតកាល ប្រាប់ពីទីតាំងដែលយើងកំពុងស្ថិតនៅបច្ចុប្បន្ន និងទិសដៅត្រូវទៅនាពេលអនាគត ។ ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីប្រវត្តិសាស្ត្រ ។ ខ្ញុំតែងតែធ្វើការសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រជាប្រចាំ ជាពិសេសប្រវត្តិរបស់ប្រទេសកម្ពុជាយើង ដើម្បីស្វែងយល់អំពីរឿងរ៉ាវទាំងឡាយដែលបានកើតមានតាមសម័យកាលនីមួយៗ និងយកមកធ្វើជាមេរៀនសម្រាប់ចង្អុលទិស ក្នុងការអនុវត្តការងារនាពេលបច្ចុប្បន្ននិងទៅអនាគត ។

តាមរយៈការសិក្សាស្រាវជ្រាវរបស់ខ្ញុំ ខ្ញុំអាចនិយាយបានថា ប្រវត្តិសាស្ត្រ គឺជាឃ្លាំងនៃបទពិសោធន៍ដ៏សម្បូរបែប ដែលកត់ត្រាពីរឿងរ៉ាវពីអតីតកាល ។ ប្រវត្តិសាស្ត្រអាចបង្រៀនយើងលើច្រើនទិដ្ឋភាព លើច្រើនមុខវិជ្ជា និងបង្ហាញពីបទពិសោធន៍នៃការគ្រប់គ្រងនិងដឹកនាំ ហើយប្រាប់យើងឱ្យដឹងពីចំណុចខ្លាំង ចំណុចខ្សោយ និងចំណុចខ្វះខាតគួរត្រូវបំពេញ ។ ការដែលមិនយល់ច្បាស់ពីប្រវត្តិសាស្ត្ររបស់ខ្លួនឯង ប្រៀបដូចជាយើងពុំស្គាល់ខ្លួនឯងដូច្នេះដែរ ។ បើយើងដឹងមិនច្បាស់ទេ ឬយើងមិនស្គាល់ខ្លួនឯងច្បាស់ទេ នោះកំហុសឆ្គងដែលធ្លាប់កើតមានវាអាចនឹងកើតឡើងវិញម្តងទៀត ។ ភាសាអង់គ្លេស យើងនិយាយថា History repeats itself ។

២/-ប្រវត្តិរូបិយវត្ថុនៅកម្ពុជា : លោក ហ្សង់ ម៉ីយែរ និយាយថា " រឿងរ៉ាវប្រវត្តិមនុស្សដែលកើតឡើងសំខាន់ជាងគេ គឺរឿងរ៉ាវពាក់ព័ន្ធនឹងរឿងហិរញ្ញវត្ថុនេះហើយ ឯរឿងអ្វីៗផ្សេងទៀត ភាគច្រើនគឺវាកើតឡើងតាមក្រោយ " ។ រូបិយវត្ថុមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជាតិមួយ ។ ក្រៅពីតម្លៃផ្នែកសេដ្ឋកិច្ច រូបិយវត្ថុមានអត្ថន័យខាងផ្នែកនយោបាយ គឺតំណាងឱ្យអធិបតេយ្យភាពជាតិ វប្បធម៌និងអរិយធម៌ជាតិ ឯករាជ្យភាពជាតិ និងការលាតសន្ធឹងនៃអំណាចសេដ្ឋកិច្ចរបស់រដ្ឋ ។ ជាងនេះទៅទៀត សេដ្ឋវិទូ ប្រវត្តិវិទូ សង្គមវិទូ នរវិទូ និងអ្នកនយោបាយបានទទួលស្គាល់ថា នៅក្នុងសង្គមយើងបច្ចុប្បន្ន រូបិយវត្ថុក៏តំណាងឱ្យអំណាចក្នុងការសម្រេចចិត្តលើនយោបាយសេដ្ឋកិច្ច អំណាចធ្វើឱ្យមានសណ្តាប់ធ្នាប់សង្គម និងជាតំណាងកម្លាំងចលករសម្រាប់ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គមឱ្យរស់រវើក ពោលគឺរូបិយវត្ថុគឺជាប្រេងរំអិលក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

តាមប្រវត្តិសាស្ត្រ រូបិយវត្ថុបានចាប់ផ្តើមកកើតឡើងតាំងពីសតវត្សរ៍ទី៧-៨ មុនគ្រិស្តសករាជ ប៉ុន្តែប្រទេសកម្ពុជាយើងបានចាប់ផ្តើមប្រើប្រាស់រូបិយវត្ថុ យឺតយ៉ាវជាងប្រទេសនានាក្នុងតំបន់និងពិភពលោក ។ នេះក៏ដោយសារតែសេដ្ឋកិច្ចយើងពឹងផ្អែកជាសំខាន់តែទៅលើវិស័យកសិកម្ម ។ ប្រជាជនខ្មែរយើងមានវប្បធម៌

ចែករំលែកឱ្យគ្នាទៅវិញទៅមក ឬដោះដូរគ្នាដោយប្រើរបស់និងរបស់ មិនទាន់ទម្លាប់ការដោះដូរដោយប្រើរូបិយវត្ថុទេ ។ រហូតដល់ដើមសតវត្សរ៍ទី១៦ ក្នុងរាជ្យព្រះស្រីជេដ្ឋាធិរាមាធិបតី ហៅ ស្តេចកន ទើបប្រទេសកម្ពុជាយើងបានបោះរូបិយវត្ថុជាតិខ្មែរដំបូងបំផុតឈ្មោះថា *ប្រាក់ស្លឹង* ដាក់ឱ្យចរាចរនៅក្នុងប្រទេស ដើម្បីជួយសម្រួលការដោះដូរទំនិញពាណិជ្ជកម្មជាមួយបរទេស ។

នៅសម័យអាណានិគមនិយមបារាំង អគ្គទេសាភិបាលឥណ្ឌូចិនបានសម្រេចបោះផ្សាយរូបិយវត្ថុរួមសម្រាប់ដាក់ឱ្យចរាចរនៅក្នុងប្រទេសទាំងបីនៃឥណ្ឌូចិន រួមមាន កម្ពុជា វៀតណាម និងឡាវ ។ ពេលនោះរាល់ការសម្រេចចិត្តលើការគ្រប់គ្រងរូបិយវត្ថុ គឺស្ថិតនៅក្រោមបារាំង កម្ពុជាយើងមានរូបិយវត្ថុចរាចរក្នុងប្រទេសទូលំទូលាយក៏ពិតមែន ប៉ុន្តែយើងពុំមានអធិតេយ្យភាពនោះទេ ។

ក្រោយពីទទួលបានឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ កម្ពុជាបានបង្កើតធនាគារកណ្តាល និងបានបោះផ្សាយប្រាក់រៀលដោយខ្លួនឯង ។ ប៉ុន្តែគួរឱ្យសោកស្តាយ របបប្រល័យពូជសាសន៍ប៉ុល ពត បានចូលមកដល់នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ បានកាប់សម្លាប់ប្រជាជនស្លូតត្រង់ បានបំផ្លាញចោលអ្វី១ទាំងអស់ រួមទាំងប្រព័ន្ធរូបិយវត្ថុនិងហិរញ្ញវត្ថុ ពោលគឺបានលុបបំបាត់លុយកាក់ ឬកម្មសិទ្ធិស្របច្បាប់ផ្សេង១ទៀត ដែលជាកម្លាំងញើសឈាមរបស់ប្រជាជនកម្ពុជាចោលអស់ តែក្នុងរយះពេលមួយថ្ងៃ ។

ក្រោយថ្ងៃមហាជ័យជំនះ ៧ មករា ១៩៧៩ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម សម្តេចអគ្គមហាពញាចក្រី ហេង សំរិន និង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្រុមប្រឹក្សាបដិវត្តប្រជាជនកម្ពុជា បានបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ និងបានបោះរូបិយវត្ថុជាតិ *"រៀល"* ឡើងវិញនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ដើម្បីរួមចំណែកអភិវឌ្ឍជាតិមាតុភូមិ និងបង្ហាញពីអធិបតេយ្យភាពជាតិខ្មែរនៅលើឆាកអន្តរជាតិ ។

ខ្ញុំនៅចាំបានថា នៅឆ្នាំ១៩៨០ បន្ទាប់ពីបានបោះផ្សាយប្រាក់រៀលដាក់ឱ្យចរាចរឡើងវិញ ប្រាក់រៀលត្រូវបានទទួលការស្វាគមន៍ និងគាំទ្រយ៉ាងខ្លាំងពីសំណាក់ប្រជាជនកម្ពុជា ។ ពេលនោះ ប្រាក់រៀលដើរតួនាទីយ៉ាងសកម្មក្នុងការជំរុញសេដ្ឋកិច្ចកម្ពុជា ដោយធ្វើជាមធ្យោបាយសម្រាប់ដោះដូរទំនិញ ជាបៀវត្សសម្រាប់បើកជូនមន្ត្រីបុគ្គលិករដ្ឋ និងជាឥណទានខ្នាតតូចសម្រាប់ការស្តារនិងអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដូចមានក្នុងសុន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានថ្លែងនៅក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ នៅសាលសន្និសីទចតុមុខ កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ កន្លងមក ។

៣/-តួនាទីប្រព័ន្ធរូបិយវត្ថុនិងហិរញ្ញវត្ថុក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ : ប្រព័ន្ធរូបិយវត្ថុគឺជាវិស័យសេដ្ឋកិច្ចមួយដ៏សំខាន់ មុនការអភិវឌ្ឍនានាអាចដំណើរការទៅបាន ។ ប្រព័ន្ធរូបិយវត្ថុអនុញ្ញាតឱ្យប្រទេសមួយមានស្តង់ដារនៃតម្លៃ និងការវាស់វែងភោគទ្រព្យយ៉ាងត្រឹមត្រូវ ហើយលុបបំបាត់ភាពស្មុគស្មាញនៃការកំណត់ថ្លៃទំនិញនិងសេវា និងការដោះដូរដែលកើតមាននៅក្នុងប្រព័ន្ធដោះដូររបស់និងរបស់ ។

នៅប្រទេសជឿនលឿនដែលមានប្រព័ន្ធហិរញ្ញវត្ថុរឹងមាំនិងទំនើប គេចាត់ទុកប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុជាបេះដូងក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ព្រោះប្រព័ន្ធធនាគារបានដើរតួនាទីជាអន្តរការិយកម្មហិរញ្ញវត្ថុ ក្នុងការកៀងគរប្រភពធនធានហិរញ្ញវត្ថុដ៏កម្រ សម្រាប់ផ្តល់ហិរញ្ញប្បទានដល់សហគ្រាសអាជីវកម្មនិងសេវាកម្ម ដែលមានតម្រូវការ ។ តាមរយៈអន្តរការិយកម្មហិរញ្ញវត្ថុ វិនិយោគិនអាចប្រមូលប្រាក់សញ្ញើដែលនៅទំនេរ យកទៅពង្រីកគម្រោងវិនិយោគរបស់ខ្លួន ។ ការពង្រីកគម្រោងវិនិយោគនឹងនាំមកនូវឱកាសការងារ បច្ចេកវិទ្យាថ្មីៗ ឯកទេសកម្ម ការប្រកួតប្រជែងផ្នែកផលិតកម្ម និងផលិតផលដែលជាប្រយោជន៍ដល់ប្រជាជននិងប្រទេសជាតិ ។ ស្ថិរភាពនៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ នាំមកនូវជំនឿទុកចិត្តចំពោះវិនិយោគិននិងសាធារណជនទូទៅ បង្ហាញពីភាពរឹងមាំនៃខឿនសេដ្ឋកិច្ចនិងល្បឿននៃកំណើនក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ។ ភាពទន់ខ្សោយនៃប្រព័ន្ធហិរញ្ញវត្ថុធ្វើឱ្យប៉ះពាល់ដល់ជំនឿទុកចិត្តសាធារណជន និងធ្វើឱ្យល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចថយចុះ ជាក់ស្តែង នាពេលថ្មីៗនេះ វិបត្តិទីផ្សារហិរញ្ញវត្ថុសកល បានធ្វើឱ្យកំណើនសេដ្ឋកិច្ចពិភពលោកធ្លាក់ចុះ ។

ក្នុងការរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាពស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកន្លងមក ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ បានដើរតួនាទីស្នូលក្នុងការធានាស្ថិរភាពរូបិយវត្ថុនិងរួមចំណែកថែរក្សាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ ។ ឋិតនៅក្នុងបរិការនេះ ធនាគារជាតិនៃកម្ពុជា បានខិតខំរក្សាលំនឹងតម្លៃប្រាក់រៀល រក្សាអំណាចទិញនៅលើទីផ្សារ សំដៅពង្រឹងជំនឿទុកចិត្តរបស់សាធារណជននិងបង្កើនតួនាទីប្រាក់រៀលក្នុងសេដ្ឋកិច្ច ។ ធនាគារជាតិនៃកម្ពុជា តែងតែខិតខំប្រឹងប្រែងរក្សាស្ថិរភាពហិរញ្ញវត្ថុ តាមរយៈការត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជាជាប់ជាប្រចាំ ។

ជាលទ្ធផល ក្នុងរយៈពេល៣០ឆ្នាំមកនេះ យើងបានរួមគ្នាកសាងប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើន ទាំងផ្នែកវិសាលភាពនិងទំហំសកម្មភាព ។ ប្រាក់បញ្ញើរបស់អតិថិជនក្នុងប្រព័ន្ធធនាគារនិងឥណទានចំពោះវិស័យឯកជនបានកើនឡើង ហើយឥណទានមិនដំណើរការ (NPL) បានថយចុះ ក្នុងកម្រិតអាចគ្រប់គ្រងបាន ។ នេះបញ្ជាក់ថា ប្រព័ន្ធធនាគាររឹងមាំ មានស្ថិរភាព និងជាអន្តរការិយកម្មហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ហើយជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ បានកើនឡើងជាលំដាប់ ។

ប្រវត្តិនៃការវិវត្តរីកចម្រើននេះ ជារឿងរ៉ាវដ៏សែនវែងឆ្ងាយនៃប្រវត្តិសាស្ត្រ ដែលបានចំណាយពេលវេលាធនធាន និងការតស៊ូព្យាយាមប្រកបដោយស្មារតីលះបង់របស់ប្រជាជនកម្ពុជា ។ ការរីកចម្រើននេះ អាចឆ្លុះបញ្ចាំងតាមរយៈផលិតផលហិរញ្ញវត្ថុថ្មីៗ និងមធ្យោបាយទូទាត់ទំនើបៗ ដូចជា ការប្រើមូលប្បទានប័ត្រ ប័ណ្ណឥណទានប័ណ្ណឥណពន្ធ ការទូទាត់ដោយឆូតកាត សេវាផ្ទេរប្រាក់តាមទូរស័ព្ទ ព្រមទាំងសេវាផ្សេងៗទៀត ដូចប្រទេសអភិវឌ្ឍដែរ ។ ទន្ទឹមនឹងនេះ វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានហេដ្ឋារចនាសម្ព័ន្ធរឹងមាំដល់ជនបទ ហើយត្រូវបានគេចាត់ថា ជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជា ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

ផ្អែកតាមប្រវត្តិសាស្ត្រ យើងអាចនិយាយបានថា ការវិវត្តរីកចម្រើនរបស់ប្រជាជាតិមួយ ផ្អែកលើកត្តាសំខាន់ពីរ *ទី១/*-ការធ្វើសង្គ្រាមដណ្តើមអំណាចរដ្ឋ វាតទីយកទឹកដីនិងដណ្តើមប្រជាជន ដើម្បីរៀបចំច្បាប់ទម្លាប់គ្រប់គ្រងទឹកដីនោះ ។ ក៏ប៉ុន្តែ ការធ្វើបែបនោះ គឺបានត្រឹមតែព្រំដែនណាមួយកំណត់ប៉ុណ្ណោះ ។ *ទី២/*-ការធ្វើសង្គ្រាមពាណិជ្ជកម្មដណ្តើមទីផ្សារ គឺមានលក្ខណៈទូលំទូលាយលើសពីដែនអធិបតេយ្យរបស់ខ្លួន ដែលគេហៅថា ការពង្រីកអំណាចខាងសេដ្ឋកិច្ច ។ ការវាតទីផ្នែកសេដ្ឋកិច្ចនេះ ទើបមានវិសាលភាពទូលំទូលាយលើសពីទីតាំងភូមិសាស្ត្រដែលយើងបានកំណត់ និងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើផ្នែកសង្គមកិច្ច វប្បធម៌ និងនយោបាយទាំងនៅក្នុងតំបន់និងពិភពលោកទាំងមូល ។

ការពង្រីកសកម្មភាពដោះដូរពាណិជ្ជកម្ម ទើបមានអត្ថន័យជ្រាលជ្រៅជាង ។ សកម្មភាពដោះដូរពាណិជ្ជកម្មជួយជំរុញឱ្យសកម្មភាពសេដ្ឋកិច្ចរីកចម្រើន និងកែប្រែជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង ។ ការលាតសន្ធឹងនៃអំណាចទីផ្សារ តាមរយៈការធ្វើពាណិជ្ជកម្មនេះ ធ្វើឱ្យពិភពលោកយើងកាន់តែមានលក្ខណៈសមាហរណកម្មខ្លាំងឡើង ។ ក្នុងការធ្វើពាណិជ្ជកម្ម រាល់ការដោះដូរទំនិញតែងតែមានមធ្យោបាយដោះដូរ ដែលយើងហៅថា " *រូបិយវត្ថុ* " ។

សរុបមក រូបិយវត្ថុមានសារៈសំខាន់ណាស់ និងមានតួនាទីចាំបាច់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង ។ ការបង្កើតធនាគារកណ្តាលនិងការបោះផ្សាយរូបិយវត្ថុជាតិដាក់ឱ្យចរាចរឡើងវិញ គឺជាផ្នែកមួយនៃការកសាងអធិបតេយ្យភាពជាតិ និងអំណាចខាងសេដ្ឋកិច្ចរបស់រដ្ឋ ។ រឿងលុយទាក់ទងនឹងជំនឿទុកចិត្ត ហើយការកសាងជំនឿទុកចិត្ត គឺទាមទាររយៈពេលយូរ ប៉ុន្តែជំនឿទុកចិត្តងាយស្រួលនឹងបាត់បង់ទៅវិញណាស់ ។ លុយគឺជាអ្វីដែលយើងទាំងអស់គ្នាបង្កើតឡើង លុយជារបស់យើង ។ ទាំងនេះ គឺជាសមិទ្ធផលប្រវត្តិសាស្ត្រយ៉ាងសំខាន់បំផុតសម្រាប់ប្រទេសនិងប្រជាជនកម្ពុជា ក្រោយថ្ងៃរំដោះ ៧ មករា លើរបបប្រល័យពូជសាសន៍ប៉ុល ពត ។ ដូច្នេះ យើងគ្រប់ៗគ្នាត្រូវតែមានស្មារតីរួមមួយ ក្នុងការថែរក្សានិងប្រើប្រាស់ប្រាក់រៀលរបស់យើង ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

ដើម្បីឱ្យសិក្ខាសាលាយើង បានស្វែងយល់ពីប្រវត្តិរឿងរ៉ាវសំខាន់ៗទាក់ទងនឹងការវិវត្ត និងការប្រើប្រាស់រូបិយវត្ថុនៅកម្ពុជាចាប់តាំងពីសម័យហ្វូណនរហូតមកដល់បច្ចុប្បន្ននេះ ។ ខ្ញុំសូមអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាទាំងអស់ ស្តាប់បទឧទ្ទេសនាមរបស់លោក ហ្សង់ដានីញ៉ែល ហ្គារខ៊ែរ ជាអ្នកនិពន្ធសៀវភៅ *រូបិយវត្ថុ* និងអធិបតេយ្យភាព ។ សូមអញ្ជើញលោក ហ្សង់ ដានីញ៉ែល ហ្គារខ៊ែរ និង ឯកឧត្តម ស៊ុំ សន្និសិទ្ធ។

**សូមអរគុណ!**